ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

G-4329

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៧៤៦ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើវិសោធនកម្មច្បាប់នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន
- បានឃើញប្រកាសលេខ ០៨៧ ដ.ន.ស.ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី
- បានឃើញចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម៖

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍ រវាងអ្នកអភិវឌ្ឍ និងអ្នកប្រើប្រាស់
- បង្ការទប់ស្កាត់ហានិភ័យហិរញ្ញវត្ថុ ក្នុងវិស័យអចលនវត្ថុ
- ធានាចីរភាពនៃការអភិវឌ្ឍវិស័យអចលនវត្ថុ សំដៅបង្កើនជំនឿទុកចិត្ត ដើម្បីជំរុញកំណើនសេដ្ឋកិច្ច
- រួមចំណែកទប់ស្កាត់សកម្មភាពលាងសម្អាតប្រាក់ ក្នុងវិស័យអាជីវកម្មអភិវឌ្ឍអចលនវត្ថុ។

**ប្រការ២.**

ប្រកាសនេះ មានគោលដៅកំណត់យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើសកម្មភាពពាក់ព័ន្ធអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.**

និយមន័យនៃបច្ចេកសព្ទ ក្នុងប្រកាសនេះ ត្រូវបានកំណត់ ដូចខាងក្រោម៖

- **ក្រសួង** សំដៅដល់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **នាយកដ្ឋាន** សំដៅដល់ នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។
- **អ្នកអភិវឌ្ឍអចលនវត្ថុ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ធ្វើសកម្មភាពអាជីវកម្មអភិវឌ្ឍលំនៅឋាន និង/ឬ អគារសហកម្មសិទ្ធិ និង/ឬអភិវឌ្ឍដីឡូត៍សម្រាប់លក់ ឬជួលរយៈពេលវែង។
- **អគារសហកម្មសិទ្ធិ** សំដៅដល់ អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ ឬអាស្រ័យផល។ អគារសហកម្មសិទ្ធិ ទាំងនោះមានជាអាទិ ខុនដូរ អគារការិយាល័យ និងអគារផ្សារជាដើម។
- **ជួលរយៈពេលវែង** សំដៅដល់ ការជួលដី ឬអគាររយៈពេលចាប់ពី ១៥ឆ្នាំឡើងទៅ។
- **រូបវន្តបុគ្គល** សំដៅដល់អ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើអាជីវកម្មអចលនវត្ថុមិនអចិន្ត្រៃយ៍។
- **អាជីវកម្មអភិវឌ្ឍអចលនវត្ថុ** សំដៅដល់សកម្មភាពអាជីវកម្មនៃការអភិវឌ្ឍលំនៅឋាន និង/ឬអគារសហកម្មសិទ្ធិ និង/ឬការអភិវឌ្ឍដីឡូត៍សម្រាប់លក់។
- **អ្នកទិញ** សំដៅដល់អតិថិជនដែលទិញលំនៅឋាន អគារសហកម្មសិទ្ធិ ឬដីឡូត៍ ពីអ្នកអភិវឌ្ឍអចលនវត្ថុ។
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតគតិយុត្តដែលចេញដោយក្រសួង ដើម្បីអនុញ្ញាតឱ្យអ្នកអភិវឌ្ឍអចលនវត្ថុយកទៅប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន និង/ឬអគារសហកម្មសិទ្ធិ និង/ឬអភិវឌ្ឍដីឡូត៍ដោយស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ។
- **លិខិតអនុញ្ញាតអាជីវកម្ម** សំដៅដល់លិខិតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យអ្នកអភិវឌ្ឍអចលនវត្ថុយកទៅប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន និង/ឬអគារសហកម្មសិទ្ធិ និង/ឬអភិវឌ្ឍដីឡូត៍ដោយស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ។
- **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ការផ្សព្វផ្សាយព័ត៌មាន តាមគ្រប់រូបភាពដើម្បីជាការជូនដំណឹង ឬបញ្ចុះបញ្ចូលដល់អ្នកទិញ ឬសាធារណជនក្នុងគោលបំណងឱ្យមកទិញអចលនវត្ថុរបស់ខ្លួន។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**ប្រការ៥.**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុ។

ក្រសួង មាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាសេនាធិការ ក្នុងការបំពេញមុខងារ និងភារកិច្ចនេះ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញភារកិច្ចសម្របសម្រួល និងគាំទ្រការងារគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅតាមរាជធានី-ខេត្ត ក្នុងនាមជាសេនាធិការ របស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## កិច្ចដំណើរការអាជីវកម្ម និងអាជ្ញាបណ្ណ

**ប្រការ៦.**

រាល់ការធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុក្នុងគោលបំណងសម្រាប់លក់ ឬជួលរយៈពេលវែង ត្រូវមានអាជ្ញាបណ្ណ

ពីក្រសួង ឬលិខិតអនុញ្ញាតអាជីវកម្មពីមន្ទីរជាមុន។

ការធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលមានទំហំចាប់ពី ០៤-៣០ល្វែង ឬ០៣-៣០ភូមិគ្រឹះ ឬ០៤-៣០យូនីត ឬអាជីវកម្មអភិវឌ្ឍដីឡូត៍ដែលមានទំហំក្រោម ១០.០០០ម៉ែត្រការ៉េ (១ហិចតា) ត្រូវមានលិខិតអនុញ្ញាតអាជីវកម្មពីមន្ទីរជាមុន។

ការធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលមានទំហំលើសពី ៣០ល្វែង ឬលើសពី ៣០ភូមិគ្រឹះ ឬលើសពី ៣០យូនីត ឬអាជីវកម្មអភិវឌ្ឍដីឡូត៍ដែលមានទំហំចាប់ពី ១០.០០០ម៉ែត្រការ៉េ ( ១ហិចតា)ឡើង ត្រូវមានអាជ្ញា-បណ្ណពីក្រសួងជាមុន។

**ប្រការ៧.**

អាជ្ញាបណ្ណដែលចេញដោយក្រសួង ឬលិខិតអនុញ្ញាតអាជីវកម្មចេញដោយមន្ទីរ ដែលស្ថិតនៅក្រោមបញ្ញត្តិនៃប្រកាសនេះមាន ៖

- អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍអគារសហកម្មសិទ្ធិ និងអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍
- លិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍលំនៅឋាន លិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអគារសហកម្មសិទ្ធិ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍដីឡូត៍។

**ប្រការ៨.**

អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិដែលចេញដោយក្រសួង ឬលិខិតអនុញ្ញាតអាជីវកម្មចេញដោយមន្ទីរ ដែលស្ថិតនៅក្រោមបញ្ញត្តិនៃប្រកាសនេះចែកចេញជាពីរប្រភេទ ៖

- អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មប្រភេទ១ ផ្តល់ជូនអ្នកអភិវឌ្ឍណា ដែលសាងសង់គម្រោងចប់ជាស្ថាពរទើបប្រកាសលក់
- អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ ផ្តល់ជូនអ្នកអភិវឌ្ឍណា ដែលសាងសង់គម្រោងបណ្តើរប្រកាសលក់បណ្តើរ។

អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មមួយ ផ្តល់ជូនសម្រាប់ទីតាំងអភិវឌ្ឍតែមួយកន្លែងប៉ុណ្ណោះ។

ក្នុងករណីគម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិតែមួយហើយបែងចែកជាច្រើនដំណាក់កាល អាជ្ញាបណ្ណត្រូវបានផ្តល់សម្រាប់ដំណាក់កាលនីមួយៗនៃគម្រោងអភិវឌ្ឍនោះ។

**ប្រការ៩.**

ថ្លៃអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្ម ត្រូវបានកំណត់ទៅតាមប្រភេទ និងទំហំដូចខាងក្រោម ៖

| ប្រភេទ | ទំហំ | ថ្លៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតអាជីវកម្ម(រៀល) |
|---|---|---|
| សំណង់ផ្ទះល្វែង | ១ ផ្ទះល្វែង | ១០០.០០០រៀល/១ល្វែង |
| សំណង់ភូមិគ្រឹះ | ១ ភូមិគ្រឹះភ្លោះ | ១០០.០០០រៀល/១ភូមិគ្រឹះភ្លោះ |
| | ១ ភូមិគ្រឹះទោល | ២០០.០០០រៀល/១ភូមិគ្រឹះទោល |
| សំណង់អគារសហកម្មសិទ្ធិ | ០១-០២ បន្ទប់គេង | ១០០.០០០រៀល/១យូនីត |
| | ០៣ បន្ទប់គេងឡើង | ២០០.០០០រៀល/១យូនីត |
| ដីឡូត៍ | ម៉ែត្រការ៉េ | ១.០០០រៀល/១ម៉ែត្រការ៉េ |

ថ្លៃអាជ្ញាបណ្ណ និងថ្លៃលិខិតអនុញ្ញាតអាជីវកម្មខាងលើ ត្រូវបង់ចូលគណនីចរន្តសម្រាប់ប្រតិបត្តិការចំណូលរបស់រតនាគារជាតិ ឬរតនាគាររាជធានី-ខេត្ត នៅធនាគារពាណិជ្ជដៃគូ។

**ប្រការ១០.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលមានបំណងធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនៅនាយកដ្ឋាន ឬលិខិតអនុញ្ញាតអាជីវកម្មនៅមន្ទីរ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារអប្បបរមាដូចខាងក្រោម÷

- លិខិត និងពាក្យស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម តាមគំរូរបស់ក្រសួង ឬមន្ទីរ
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើដីដែលកំពុងធ្វើការអភិវឌ្ឍ
- លិខិតអនុញ្ញាតសាងសង់ និង/ឬលិខិតបើកការដ្ឋានសាងសង់ ដែលចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរមានសមត្ថកិច្ច
- លិខិតបើកគណនីអភិវឌ្ឍអចលនវត្ថុ (គណនីចរន្ត) នៅធនាគារពាណិជ្ជណាមួយ (ចំពោះអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២)
- លិខិតបញ្ជាក់ដើមទុន និងលិខិតបញ្ជាក់ប្រភពទុន ដើម្បីយកមកធ្វើការវិនិយោគ (អប្បបរមា ២០%(ម្ភៃ)ភាគរយ នៃថ្លៃសំណង់សរុប ឬថ្លៃសំណង់តាមដំណាក់កាល) ដែលចេញដោយគ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២)
- លិខិតដាក់ប្រាក់តម្កល់ធានាអាជីវកម្ម ២%(ពីរ)ភាគរយ នៃថ្លៃសំណង់សរុប ឬថ្លៃសំណង់តាមដំណាក់កាល (ចំពោះអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២)
- ផែនការអាជីវកម្មលម្អិតទៅតាមរយៈពេលនៃគម្រោងអភិវឌ្ឍអចលនវត្ថុ
- លិខិតថ្កោលទោសរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ដែលចេញដោយក្រសួងយុត្តិធម៌ ឬចេញដោយប្រទេសសាមី (ចំពោះជនបរទេស) និង/ឬលិខិតបញ្ជាក់កិរិយាមាយាទ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

ឯកសារលម្អិតផ្សេងទៀត ត្រូវបានកំណត់ក្នុងសៀវភៅបន្ទុក។

**ប្រការ១១.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលមានបំណងធ្វើអាជីវកម្មអភិវឌ្ឍដីឡូត៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនៅនាយកដ្ឋាន ឬលិខិតអនុញ្ញាតអាជីវកម្មនៅមន្ទីរ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារអប្បបរមាដូចខាងក្រោម÷

- លិខិត និងពាក្យស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម តាមគំរូរបស់ក្រសួង ឬមន្ទីរ
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើដីដែលកំពុងធ្វើការអភិវឌ្ឍ
- ប្លង់រួមស្តីពីការអភិវឌ្ឍដីឡូត៍
- លិខិតអនុញ្ញាតអភិវឌ្ឍដីដែលចេញដោយអាជ្ញាធរ ឬ អង្គភាពមានសមត្ថកិច្ច
- លិខិតដាក់ប្រាក់តម្កល់ធានាអាជីវកម្ម ៥%(ប្រាំ)ភាគរយ នៃតម្លៃដីវិនិយោគសរុប ឬតម្លៃដីវិនិយោគតាមដំណាក់កាលនីមួយៗ
- ផែនការអាជីវកម្មលម្អិតទៅតាមរយៈពេលនៃគម្រោងអភិវឌ្ឍអចលនវត្ថុ

- លិខិតថ្កោលទោសរបស់ម្ចាស់គម្រោងដែលចេញដោយក្រសួងយុត្តិធម៌ និង/ឬលិខិតបញ្ជាក់កិរិយាមាយាទ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

ឯកសារលម្អិតផ្សេងទៀត ត្រូវបានកំណត់ក្នុងសៀវភៅបន្ទុក។

**ប្រការ១២.**

ក្រសួង ឬមន្ទីរមានរយៈពេល ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មជូនអ្នកអភិវឌ្ឍអចលនវត្ថុ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់ចំនួន និងត្រឹមត្រូវ។

**ប្រការ១៣.**

អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម មិនអាចផ្ទេរ ឬលក់បានឡើយ។ ករណីមានការផ្លាស់ប្តូរឈ្មោះគម្រោងអភិវឌ្ឍអចលនវត្ថុ ឬឈ្មោះអ្នកអភិវឌ្ឍអចលនវត្ថុ ឬឈ្មោះភាគហ៊ុននិក ឬអ្នកឈរឈ្មោះលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតអាជីវកម្ម អ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួង ឬមន្ទីរជាមុន។

**ប្រការ១៤.**

ក្រសួង ឬមន្ទីរអាចដកហូត ឬព្យួរអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ក្នុងករណីណាមួយដូចខាងក្រោម÷

- ពុំបានអនុវត្តត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រសួង
- អ្នកអភិវឌ្ឍអចលនវត្ថុខកខានមិនបានកាន់កាប់បញ្ជីគណនេយ្យត្រឹមត្រូវ
- អ្នកអភិវឌ្ឍអចលនវត្ថុខកខានមិនបានបង់ពន្ធប៉ាតង់អាជីវកម្មអភិវឌ្ឍអចលនវត្ថុ និងមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- អ្នកអភិវឌ្ឍអចលនវត្ថុអសាធនភាព ឬក្ស័យធន ឬប្រព្រឹត្តល្មើសក្នុងការធ្វើអាជីវកម្ម ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ
- លទ្ធផលសវនកម្មបង្ហាញឱ្យឃើញថា មានភាពខុសគ្នាពាក់ព័ន្ធរបាយការណ៍ប្រចាំខែ និងរបាយការណ៍ប្រចាំត្រីមាស។
- ពុំបានអនុវត្តគម្រោងក្នុងរយៈពេល ០៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម
- ពុំបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យាលក់-ទិញឱ្យបានចប់សព្វគ្រប់
- ខកខានមិនបានផ្តល់របាយការណ៍ឱ្យបានទៀងទាត់តាមការកំណត់
- បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញប្បទានភេរវកម្ម និងការលាងសម្អាតប្រាក់ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី៤
## ភាតព្វកិច្ចរបស់អ្នកអភិវឌ្ឍអចលនវត្ថុ

**ប្រការ១៥.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មមានកាតព្វកិច្ច ដូចខាងក្រោម÷

- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ

- ត្រូវបង្ហាញព័ត៌មានអប្បបរមាដូចមានចែងក្នុងប្រការ១៧ ដល់អ្នកទិញ ក្នុងពេលចុះកិច្ចសន្យាលក់-ទិញ
- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេសនៃការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ត្រូវចុះបញ្ជីពន្ធដារ
- ត្រូវអនុវត្តទៅតាមកាលវិភាគបង់ប្រាក់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ
- ត្រូវអនុវត្តកាតព្វកិច្ចឱ្យបានចប់សព្វគ្រប់ដូចមានចែងក្នុងកិច្ចសន្យាលក់-ទិញ
- ត្រូវបំបែកក្បាលដីទៅតាមចំនួនលំនៅឋាន ឬដីឡូត៍ដែលត្រូវអភិវឌ្ឍ
- ត្រូវលើកស្លាកសញ្ញាអំពីគម្រោងអភិវឌ្ឍរបស់ខ្លួនដោយបង្ហាញគំនូរប្លង់នៃគម្រោងអភិវឌ្ឍ និងទីតាំងដែលគម្រោងអភិវឌ្ឍនោះស្ថិតនៅ
- ត្រូវផ្ទេរឈ្មោះលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិ ជូនអ្នកទិញក្រោយពេលបានបង់ប្រាក់គ្រប់ចំនួន
- ត្រូវផ្តល់របាយការណ៍មកក្រសួង ឬមន្ទីរឱ្យបានត្រឹមត្រូវ និងទៀងទាត់ដូចបានកំណត់ក្នុងប្រកាសនេះ។

**ប្រការ១៦.**

ត្រូវចៀសវាងការចូលរួម ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសហិរញ្ញប្បទានភេរវកម្ម និងការលាងសម្អាតប្រាក់ ឬអំពើមិនស្របច្បាប់ណាមួយដែលច្បាប់ហាមឃាត់។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវរាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងត្រូវចម្លងជូនជាលាយលក្ខណ៍អក្សរមកក្រសួង ឬមន្ទីរ។

## ជំពូកទី៥

## កាតព្វកិច្ចរបស់អ្នកទិញ

**ប្រការ១៧.**

អ្នកទិញអចលនវត្ថុពីអ្នកអភិវឌ្ឍមានកាតព្វកិច្ចដូចខាងក្រោម÷

- ត្រូវពិនិត្យខ្លឹមសារលម្អិតនៃកិច្ចសន្យាលក់-ទិញមុនសម្រេចចិត្តចុះហត្ថលេខា ឬ ផ្តិតមេដៃ
- ត្រូវពិនិត្យអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលចេញដោយក្រសួង ឬមន្ទីរ
- ត្រូវពិនិត្យវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឱ្យបានច្បាស់លាស់
- ត្រូវពិនិត្យមើលទិន្នន័យ ឬឯកសារបំបែកក្បាលដី
- ត្រូវពិនិត្យកិច្ចសន្យាលក់-ទិញអចលនវត្ថុពីម្ចាស់ដើម (ករណីដីទិញពីគេ)
- ត្រូវពិនិត្យឯកសារចុះបញ្ជីពន្ធដារ
- ត្រូវពិនិត្យឈ្មោះ អត្តសញ្ញាណបណ្ណ និងអាសយដ្ឋានម្ចាស់គម្រោងពិតប្រាកដ។

## ជំពូកទី៦

## ការផ្សាយពាណិជ្ជកម្ម

**ប្រការ១៨.**

ការផ្សាយពាណិជ្ជកម្មអំពីគម្រោងអភិវឌ្ឍអចលនវត្ថុតាមគ្រប់រូបភាព ត្រូវបានហាមឃាត់ចំពោះគម្រោងណាដែលមិនទាន់មានអាជ្ញាបណ្ណពីក្រសួង ឬលិខិតអនុញ្ញាតអាជីវកម្មពីមន្ទីរ។

**ប្រការ១៩.**

ការផ្សាយពាណិជ្ជកម្មរបស់អ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវបង្ហាញនូវព័ត៌មានអប្បបរមាមួយចំនួនដូចខាងក្រោម÷

- ឈ្មោះ និងទីតាំងគម្រោង
- អាជ្ញាបណ្ណនិងអត្តលេខអាជ្ញាបណ្ណដែលចេញដោយក្រសួង ឬលិខិតអនុញ្ញាតអាជីវកម្មដែលចេញដោយមន្ទីរ
- លិខិតអនុញ្ញាតដែលចេញដោយអាជ្ញាធរ ឬអង្គភាពមានសមត្ថកិច្ចផ្សេងទៀត
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (បើអចលនវត្ថុនោះជួលពីរដ្ឋ ត្រូវបង្ហាញពីកាលបរិច្ឆេទផុតកំណត់)
- តម្លៃនៃប្រភេទអចលនវត្ថុនីមួយៗដែលត្រូវលក់
- កាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់គម្រោង
- ឈ្មោះម្ចាស់គម្រោងអភិវឌ្ឍអចលនវត្ថុ។

**ប្រការ២០.**

ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីគម្រោងអភិវឌ្ឍអចលនវត្ថុ ដែលមានលក្ខណៈជាការឆបោក ឬមានលក្ខណៈមិនសុចរិត ឬជាការបំភាន់ដោយការសន្យាផ្តល់ជាអំណោយ ឬរង្វាន់ដើម្បីជាការទាក់ទាញ ប៉ុន្តែមិនបានអនុវត្តតាមការសន្យា ឬនាំឱ្យមានការយល់ខុស ឬធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ត្រូវបានហាមឃាត់ជាដាច់ខាត។

## ជំពូកទី៧
## កិច្ចសន្យាលក់-ទិញ

**ប្រការ២១.**

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ១ អាចដំណើរការប្រតិបត្តិការលក់-ទិញបាន លុះត្រាតែអ្នកអភិវឌ្ឍនោះបានបញ្ចប់គម្រោងសាងសង់ជាស្ថាពរដោយមានលិខិតបិទការដ្ឋាន លិខិតបញ្ជាក់ពីគុណភាពសំណង់ និង/ឬមានការវាយតម្លៃពីមន្ត្រីជំនាញរបស់នាយកដ្ឋាន ឬមន្ទីរជាមុន។

**ប្រការ២២.**

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ អាចដំណើរការប្រតិបត្តិការលក់បាន លុះត្រាតែមានលិខិតអនុញ្ញាតសាងសង់ និង/ឬលិខិតបើកការដ្ឋានសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីដែលមិនទាន់មានលិខិតអនុញ្ញាតសាងសង់ និង/ឬលិខិតបើកការដ្ឋានសាងសង់ អ្នកអភិវឌ្ឍមានសិទ្ធិទទួលប្រាក់កក់ដំបូងត្រឹមតែ ១%(មួយ)ភាគរយនៃតម្លៃលក់ប៉ុណ្ណោះ។ ប្រាក់កក់ដំបូងនេះ ត្រូវរក្សាទុកនៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុ និងមិនអនុញ្ញាតឱ្យដកយកទៅប្រើប្រាស់ទេលុះត្រាតែទទួលបានលិខិតអនុញ្ញាតសាងសង់ និងលិខិតបើកការដ្ឋានសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ចំពោះគម្រោងដែលក្រសួង ឬអាជ្ញាធរមិនផ្តល់លិខិតអនុញ្ញាតសាងសង់ និង/ឬលិខិតបើកការដ្ឋានសាងសង់ជូន ប្រាក់កក់ដំបូងនេះត្រូវប្រគល់ជូនទៅអ្នកទិញវិញជាកំហិត។

**ប្រការ២៣.**

កិច្ចសន្យាលក់-ទិញអចលនវត្ថុ ត្រូវចែងឱ្យបានច្បាស់នូវព័ត៌មានអប្បបរមាមួយចំនួនដូចខាងក្រោម ÷

- ឈ្មោះអ្នកអភិវឌ្ឍ និងឈ្មោះអ្នកទិញ ដោយបញ្ជាក់អំពីអត្តសញ្ញាណ និងអាសយដ្ឋានរបស់ភាគីទាំងពីរឱ្យបានច្បាស់ និងមានសាក្សីដឹងឮ

- ទីតាំងគម្រោង ទំហំដី និងតម្លៃលក់-ទិញដែលបានព្រមព្រៀងគ្នា
- កាតព្វកិច្ចរបស់គូភាគីដែលទទួលបន្ទុកបង់ពន្ធប្រថាប់ត្រា និងបង់កម្រៃសេវាផ្សេងៗទៀត
- កាលបរិច្ឆេទបញ្ចប់គម្រោង
- ឈ្មោះ ទីតាំងរបស់ធនាគារ និងលេខគណនីអភិវឌ្ឍអចលនវត្ថុ ដែលអ្នកអភិវឌ្ឍត្រូវបើកតាមប្រការ៣០ នៃប្រកាសនេះ(ចំពោះអ្នកអភិវឌ្ឍដែលទទួលបានអាជ្ញាបណ្ណប្រភេទ២)
- នីតិវិធី និងកាលវិភាគបង់ប្រាក់
- ចំនួនទឹកប្រាក់ដែលត្រូវធ្វើការផាកពិន័យចំពោះការបង់ប្រាក់យឺតយ៉ាវ ត្រូវតែសមាមាត្រទៅនឹងចំនួនទឹកប្រាក់ដែលត្រូវធ្វើការផាកពិន័យចំពោះការសាងសង់យឺតយ៉ាវ
- សិទ្ធិរបស់អ្នកទិញពាក់ព័ន្ធទៅនឹងដី ឬលំហចំណែកឯកជន និងចំណែករួម
- សិទ្ធិក្នុងការរំលាយកិច្ចសន្យា
- កាតព្វកិច្ចក្នុងការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិ
- ការធានាខុសត្រូវលើគុណភាព និងសុវត្ថិភាពសំណង់
- ប្រសិនបើដីអភិវឌ្ឍនោះ ជាដីជួលពីរដ្ឋ ឬឯកជន អ្នកអភិវឌ្ឍត្រូវបញ្ជាក់អំពីរយៈពេលដែលអ្នកទិញមានសិទ្ធិកាន់កាប់អចលនវត្ថុ និងអំពីថ្ងៃខែចាប់ផ្តើម និងថ្ងៃខែដែលត្រូវបញ្ចប់សិទ្ធិនៃការជួលដីនោះ
- ប្រសិនបើដីអភិវឌ្ឍនោះជាប់បន្ទុក ត្រូវប្រកាសប្រាប់អ្នកទិញអំពីក្បាលដីជាប់បន្ទុកផ្សេងៗ និងត្រូវធានាការផ្ទេរកម្មសិទ្ធិស្របច្បាប់ បន្ទាប់ពីអ្នកទិញបានអនុវត្តកាតព្វកិច្ចបង់ប្រាក់រួចរាល់។

**ប្រការ២៤.**

សិទ្ធិក្នុងការចុះកិច្ចសន្យាលក់-ទិញអចលនវត្ថុ ត្រូវបានអនុញ្ញាតចំពោះតែអ្នកអភិវឌ្ឍណា ដែលជាម្ចាស់កម្មសិទ្ធិលើដីធ្លីនៃគម្រោងអភិវឌ្ឍនោះតែប៉ុណ្ណោះ។ ចំពោះអ្នកអភិវឌ្ឍណា ដែលមិនមែនជាម្ចាស់កម្មសិទ្ធិលើដីធ្លី មានសិទ្ធិអាចចុះកិច្ចសន្យាលក់-ទិញបាន លុះត្រាតែមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិលើដីធ្លីនោះស្របទៅតាមនីតិវិធីច្បាប់ជាធរមាន។

## ជំពូកទី៨
## ប្រាក់តម្កល់ធានាអាជីវកម្ម

**ប្រការ២៥.**

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ២%(ពីរ)ភាគរយ នៃតម្លៃសំណង់សរុប ឬតម្លៃសំណង់តាមដំណាក់កាលនីមួយៗ ទៅតាមវិធីសាស្ត្រណាមួយដូចខាងក្រោម ÷

ក. តម្កល់ជាសាច់ប្រាក់ក្នុងគណនីទោលរតនាគារជាតិ ដែលបើកនៅធនាគារជាតិនៃកម្ពុជា ឬនៅធនាគារពាណិជ្ជក្នុងស្រុកណាមួយ ឬជា

ខ. លិខិតធានាពីធនាគារពាណិជ្ជក្នុងស្រុកណាមួយដែលមានតម្លៃស្មើ។

អ្នកអភិវឌ្ឍដីឡូត៍ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ៥% (ប្រាំ)ភាគរយ នៃតម្លៃដីវិនិយោគសរុប ឬតម្លៃវិនិយោគតាមដំណាក់កាលនីមួយៗ ទៅតាមវិធីសាស្ត្រណាមួយដូចខាងក្រោម ÷

ក. តម្កល់ជាសាច់ប្រាក់ក្នុងគណនីទោលរតនាគារជាតិ ដែលបើកនៅធនាគារជាតិនៃកម្ពុជា ឬនៅធនាគារពាណិជ្ជក្នុងស្រុកណាមួយ ឬជា

ខ. លិខិតធានាពីធនាគារពាណិជ្ជក្នុងស្រុកណាមួយដែលមានតម្លៃស្មើ។

**ប្រការ២៦.**

ប្រាក់តម្កល់ធានាអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ អាចដកវិញបានលុះត្រាតែគម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិនោះសាងសង់បានចាប់ពី ៧០%(ចិតសិប)ភាគរយឡើង ឬចប់ជាស្ថាពរដោយមានលិខិតបិទការដ្ឋានសាងសង់ និងលិខិតបញ្ជាក់គុណភាពសំណង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង/ឬក្រោយពីមានការចុះវាយតម្លៃជាក់ស្តែងពីមន្ត្រីជំនាញរបស់នាយកដ្ឋាន ឬមន្ទីរ។ ក្នុងករណីគម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិមានច្រើនដំណាក់កាល ឬអ្នកអភិវឌ្ឍមានគម្រោងថ្មីមួយផ្សេងទៀត ប្រាក់តម្កល់ធានាអាជីវកម្មនេះអាចធ្វើការផ្ទេរពីមួយដំណាក់កាលទៅមួយដំណាក់កាល ឬពីមួយគម្រោងទៅមួយគម្រោងទៀតបាន បន្ទាប់ពីដំណាក់-កាលមុន ឬគម្រោងមុនសាងសង់បាន ៥០%(ហាសិប)ភាគរយឡើង។ ប៉ុន្តែចំនួនទឹកប្រាក់តម្កល់នោះអាចមានការប្រែប្រួលទៅតាមទំហំជាក់ស្តែងនៃការវិនិយោគរបស់គម្រោង ឬដំណាក់កាលបន្ទាប់។

ប្រាក់តម្កល់ធានាអាជីវកម្មអភិវឌ្ឍដីឡូត៍ អាចដកវិញបានលុះត្រាតែអ្នកអភិវឌ្ឍដីឡូត៍ បានបំពេញកាតព្វកិច្ចចប់សព្វគ្រប់ រួមទាំងការផ្ទេរកម្មសិទ្ធិអចលនវត្ថុជូនអ្នកទិញទៅតាមកិច្ចសន្យា និង/ឬក្រោយពីមានការចុះវាយតម្លៃជាក់ស្តែងពីមន្ត្រីជំនាញរបស់នាយកដ្ឋាន ឬមន្ទីរ។

**ប្រការ២៧.**

អ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវដាក់លិខិតស្នើសុំដកប្រាក់តម្កល់ធានាអាជីវកម្មមកក្រសួង ឬមន្ទីរដោយភ្ជាប់មកជាមួយនូវរបាយការណ៍បញ្ចប់គម្រោងទៅតាមគំរូរបស់ក្រសួង ឬមន្ទីរ។

នៅក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំដកប្រាក់តម្កល់ធានាអាជីវកម្មដោយមានភ្ជាប់ជាមួយនូវឯកសារតម្រូវផ្សេងៗគ្រប់ចំនួន និងបន្ទាប់ពីមានការចុះវាយតម្លៃជាក់ស្តែងដល់ទីកន្លែងពីមន្ត្រីជំនាញរបស់នាយកដ្ឋាន ឬមន្ត្រីជំនាញរបស់មន្ទីរ ក្រសួងឬមន្ទីរនឹងចេញលិខិតអនុញ្ញាតឱ្យដក ឬមិនអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាអាជីវកម្មនេះ។

**ប្រការ២៨.**

ក្រសួង ឬមន្ទីរមានសិទ្ធិស្នើសុំបង្កកប្រាក់តម្កល់ធានាអាជីវកម្ម ក្នុងករណីដែលក្រសួង ឬមន្ទីរពិនិត្យឃើញថាអ្នកអភិវឌ្ឍនោះពុំបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាលក់-ទិញ ឬពុំមានលទ្ធភាពសាងសង់ ឬបោះបង់ចោលការសាងសង់គម្រោងរបស់ខ្លួន ឬប្រធានសក្តិ ឬដែលបានធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងររបស់អ្នកទិញ។

ប្រាក់តម្កល់ធានាអាជីវកម្មអាចផ្តល់ជូនវិញបាន លុះត្រាតែអ្នកអភិវឌ្ឍបានចូលខ្លួនមកបំពេញកាតព្វកិច្ចឡើងវិញ។

## ជំពូកទី៩
## លំនៅឋាន ឬអគារសហកម្មសិទ្ធិគំរូ

**ប្រការ២៩.**

ចំពោះអ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ត្រូវរៀបចំលំនៅឋាន ឬអគារសហកម្មសិទ្ធិគំរូ ឱ្យបានរួចរាល់

មុនធ្វើការប្រកាសលក់។ លំនៅឋាន ឬអគារសហកម្មសិទ្ធិគំរូ ត្រូវរៀបចំដាក់ស្តែងឱ្យស្របទៅតាមគំរូប្លង់ ទំហំ ការតុបតែង និងបំពាក់សម្ភារៈសំណង់ដូចគម្រោងដែលនឹងត្រូវសាងសង់ដើម្បីលក់។

សម្ភារៈតុបតែងណាដែលអ្នកអភិវឌ្ឍមិនផ្តល់ជូន ត្រូវសរសេរបញ្ជាក់ជាលាយលក្ខណ៍អក្សរនៅលើសម្ភារៈនោះឱ្យបានច្បាស់លាស់ ដើម្បីចៀសវាងធ្វើឱ្យអ្នកទិញមានការយល់ច្រឡំ។

## ជំពូកទី១០
## គណនីអភិវឌ្ឍអចលនវត្ថុ

**ប្រការ៣០.**

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ដែលស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ១ មិនតម្រូវឱ្យបើកគណនីអភិវឌ្ឍអចលនវត្ថុឡើយ។

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ដែលស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ ត្រូវបើកគណនីអភិវឌ្ឍអចលនវត្ថុ នៅធនាគារពាណិជ្ជណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់រក្សាប្រាក់កក់ដំបូង ឬប្រាក់ត្រូវបង់តាមដំណាក់កាល ឬប្រាក់ត្រូវបង់គ្រប់ប្រភេទរបស់អ្នកទិញ។ គណនីនេះ ត្រូវស្ថិតនៅក្រោមការតាមដានជាប្រចាំពីក្រសួង ឬមន្ទីរ និងអាចបិទបានលុះត្រាតែគម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិនោះ បានបញ្ចប់ជាស្ថាពរ និងមានការឯកភាពពីក្រសួង ឬមន្ទីរ។

**ប្រការ៣១.**

ប្រាក់កក់ដំបូង ឬប្រាក់បង់តាមដំណាក់កាល ឬប្រាក់បង់គ្រប់ប្រភេទរបស់អ្នកទិញ ត្រូវបង់ដោយផ្ទាល់ទៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុរបស់អ្នកអភិវឌ្ឍ។

**ប្រការ៣២.**

ការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុ ត្រូវបានអនុញ្ញាតសម្រាប់តែការបម្រើឱ្យគោលបំណងនៃការសាងសង់គម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិនោះតែប៉ុណ្ណោះ។ ការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុនោះ ត្រូវតែសមាមាត្រទៅនឹងទំហំការងារដែលអ្នកអភិវឌ្ឍបានសាងសង់ និងត្រូវមានលិខិតបញ្ជាក់ពីវិស្វករត្រួតពិនិត្យគម្រោងរបស់អ្នកអភិវឌ្ឍ អំពីភាគរយនៃលទ្ធផលការងារដែលអ្នកអភិវឌ្ឍបានអនុវត្តកន្លងមក។

វិស្វករដែលចេញលិខិតបញ្ជាក់នោះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ពាក់ព័ន្ធជាធរមាន ក្នុងករណីចេញលិខិតបញ្ជាក់មិនត្រឹមត្រូវ ឬក្លែងបន្លំ។

**ប្រការ៣៣.**

ក្រសួង ឬមន្ទីរមានសិទ្ធិស្នើសុំបង្កកគណនីអភិវឌ្ឍអចលនវត្ថុរបស់អ្នកអភិវឌ្ឍ ក្នុងករណីដែលក្រសួង ឬមន្ទីរពិនិត្យឃើញថា អ្នកអភិវឌ្ឍនោះពុំបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាលក់-ទិញ ឬពុំមានលទ្ធភាពសាងសង់ ឬបោះបង់ចោលការសាងសង់គម្រោងរបស់ខ្លួន ឬប្រធានសក្តិ ឬដែលបានធ្វើឱ្យខូចប្រយោជន៍របស់អ្នកទិញ។

គណនីនេះ អាចដាក់ឱ្យដំណើរការវិញបាន លុះត្រាតែមានការឯកភាពជាមុនពីក្រសួង ឬមន្ទីរ។

## ជំពូកទី១១

## របាយការណ៍ និងការចុះត្រួតពិនិត្យ

**ប្រការ៣៤.**

មន្ទីរត្រូវផ្តល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រចាំត្រីមាសស្តីពីសកម្មភាពអាជីវកម្មអចលនវត្ថុឱ្យបានមុនថ្ងៃទី១៥ ខែទី០១ នៃត្រីមាសបន្ទាប់
- របាយការណ៍ចំណូលប្រចាំត្រីមាស ស្តីពីការចេញលិខិតអនុញ្ញាតអាជីវកម្មរបស់មន្ទីរ ឱ្យបានមុនថ្ងៃទី១៥ ខែទី០១ នៃត្រីមាសបន្ទាប់។

ទម្រង់របាយការណ៍ខាងលើត្រូវបានកំណត់ទៅតាមគំរូដែលក្រសួងផ្តល់ជូន។

**ប្រការ៣៥.**

អ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវផ្តល់ជូនក្រសួង ឬមន្ទីរនូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រចាំខែស្តីពីវឌ្ឍនភាពនៃការសាងសង់ ចលនាសាច់ប្រាក់នៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុ និងការលក់-ទិញរបស់គម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ (សម្រាប់អ្នកអភិវឌ្ឍដែលទទួលអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២)
- របាយការណ៍ប្រចាំត្រីមាសស្តីពីវិហ្វរសាច់ប្រាក់របស់អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ និងរបាយការណ៍ប្រតិបត្តិការនៃការលក់-ទិញដីឡូត៍របស់អ្នកអភិវឌ្ឍដីឡូត៍។

របាយការណ៍ប្រចាំខែខាងលើ ត្រូវផ្តល់ឱ្យបានមុនថ្ងៃទី០៧ នៃថ្ងៃធ្វើការនៃខែបន្ទាប់។ ចំពោះរបាយការណ៍ប្រចាំត្រីមាសត្រូវផ្តល់ឱ្យបានមុនថ្ងៃទី១៥ ខែទី១ នៃត្រីមាសបន្ទាប់។ ទម្រង់របាយការណ៍ទាំងពីរខាងលើត្រូវបានកំណត់ទៅតាមគំរូដែលក្រសួងផ្តល់ជូន។

**ប្រការ៣៦.**

ក្នុងរយៈពេល ០៣(បី)ខែ គិតចាប់ពីការបិទការិយបរិច្ឆេទ នៃឆ្នាំហិរញ្ញវត្ថុនីមួយៗ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមកក្រសួង ឬមន្ទីរ។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យ ដែលមានការទទួលស្គាល់ដោយក្រសួងឬដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៣៧.**

អ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវផ្តល់របាយការណ៍ស្តីពីការបញ្ចប់គម្រោង និងរបាយការណ៍ហិរញ្ញវត្ថុមកក្រសួង ឬមន្ទីរ ក្នុងរយៈពេល ០១(មួយ)ខែ ក្រោយកាលបរិច្ឆេទបញ្ចប់គម្រោង ទៅតាមគំរូដែលក្រសួង ឬមន្ទីរបានផ្តល់ជូន។

**ប្រការ៣៨.**

ក្រសួង ឬមន្ទីរមានសិទ្ធិចាត់តាំងមន្ត្រីជំនាញ ចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងដើម្បីធានាការគោរពតាមប្រកាសនេះ។

**ប្រការ៣៩.**

ក្រសួង ឬមន្ទីរមានសិទ្ធិតែងតាំងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មអ្នកអភិវឌ្ឍអចលនវត្ថុ ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីលើឯកសារពាក់ព័ន្ធគណនេយ្យ ដែលផ្តល់ដោយអ្នកអភិវឌ្ឍ ឬប៉ះពាល់ដល់ប្រយោជន៍សាធារណៈ។

រាល់ការចំណាយលើសវនកម្មឯករាជ្យ ជាបន្ទុករបស់អ្នកអភិវឌ្ឍអចលនវត្ថុ។

## ជំពូកទី១២
## ការផ្សះផ្សានិងដោះស្រាយវិវាទ

**ប្រការ៤០.**

វិវាទរវាងអ្នកអភិវឌ្ឍអចលនវត្ថុ និងអ្នកទិញពាក់ព័ន្ធកិច្ចសន្យាលក់-ទិញអចលនវត្ថុ អាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយក្រសួង ឬមន្ទីរ។

ក្រសួង ឬមន្ទីរសម្រុះសម្រួលនិងផ្សះផ្សាវិវាទ តាមការស្នើសុំរបស់ភាគីវិវាទក្នុងរយៈពេល ០២(ពីរ)ខែ យ៉ាងយូរ។ ការផ្សះផ្សាវិវាទ អាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីវិវាទ និងមានការទទួលដឹងឮដោយនាយកដ្ឋាន ឬមន្ទីរ។ កិច្ចព្រមព្រៀងផ្សះផ្សា មានអានុភាពអនុវត្តភ្លាមៗ ចំពោះគូភាគី។

**ប្រការ៤១.**

គូភាគីវិវាទ ដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង ឬមន្ទីរ មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការ លើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទ ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអញ្ជើញភាគីពាក់ព័ន្ធវិវាទ ដើម្បីសាកសួរ ឬផ្តល់ភស្តុតាង តាមការចាំបាច់។

សេចក្តីសម្រេចស្តីពីការដោះស្រាយវិវាទ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់អំពីអង្គហេតុ សំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១៣
## ទោសប្បញ្ញត្តិ

**ប្រការ៤២.**

ត្រូវបានចាត់ទុកជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុដោយគ្មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម
- ក្លែងបន្លំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម
- ប្រើប្រាស់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មហួសសុពលភាព
- ធ្វើឱ្យបាត់បង់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មច្បាប់ដើម មុនពេលគម្រោងសាងសង់ចប់ជាស្ថាពរ
- ការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យាលក់-ទិញ
- ការដកប្រាក់តម្កល់ធានាអាជីវកម្មដោយគ្មានការអនុញ្ញាតជាមុនពីក្រសួង ឬមន្ទីរ

- ប្រើប្រាស់លិខិតធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋានផុតសុពលភាព
- ប្រើប្រាស់លិខិតដាក់ប្រាក់តម្កល់ធានាអាជីវកម្មផុតសុពលភាព
- ប្រើប្រាស់គណនីផ្សេងពីគណនីអភិវឌ្ឍអចលនវត្ថុសម្រាប់ទទួលប្រាក់ពីអ្នកទិញ
- ផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈជាការឆបោក ឬនាំឱ្យមានការយល់ច្រឡំ
- លក់អចលនវត្ថុមុនពេលបញ្ចប់គម្រោងសាងសង់ ចំពោះអ្នកអភិវឌ្ឍទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ១
- ក្លែងបន្លំ យឺតយ៉ាវ ឬការខកខានមិនផ្ដល់របាយការណ៍តាមការកំណត់របស់ក្រសួង ឬមន្ទីរ ដូចមានចែងក្នុងប្រកាសនេះ
- ការមិនអនុវត្តគម្រោងអភិវឌ្ឍទៅតាមការកំណត់របស់ក្រសួង- ស្ថាប័ន និង អាជ្ញាធរមានសមត្ថកិច្ច
- ការមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ
- ពុំបានអនុវត្តតាមខ្លឹមសារសៀវភៅបន្ទុក
- ខកខានមិនបានកាន់កាប់បញ្ជីគណនេយ្យត្រឹមត្រូវ
- លទ្ធផលសវនកម្មបង្ហាញឱ្យឃើញថា មានភាពខុសគ្នាពាក់ព័ន្ធរបាយការណ៍ប្រចាំខែ និងរបាយការណ៍ប្រចាំត្រីមាស
- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង ឬមន្ទីរ ដោយអនុលោមតាមច្បាប់ជាធរមាន។

**ប្រការ៤៣.**

អ្នកអភិវឌ្ឍអចលនវត្ថុទាំងឡាយណាដែលបានប្រព្រឹត្តកំហុស ដូចមានចែងក្នុងប្រការ៤២ នៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម÷

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការបង្កកគណនីអភិវឌ្ឍអចលនវត្ថុ
- ហាមឃាត់ការធ្វើប្រតិបត្តិការ ឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មបណ្ដោះអាសន្ន ពី ០៦(ប្រាំមួយ)ខែ ទៅ ០១(មួយ)ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម
- បង្កកប្រាក់តម្កល់ធានាអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ
- ប្ដឹងទៅតុលាការមានសមត្ថកិច្ច។

**ប្រការ៤៤.**

ការប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិគ្មានអាជ្ញាបណ្ណ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ចំនួន ១០០.០០០.០០០(មួយរយលាន)រៀល។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ជាកពិន័យនេះត្រូវគុណទ្វេដង រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់ការបន្ត។

ការប្រកបអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិគ្មានលិខិតអនុញ្ញាតអាជីវកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ពីមន្ទីរ ចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះត្រូវគុណទ្វេដង រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់ការបន្ត។

ការប្រកបអាជីវកម្មអភិវឌ្ឍដីឡូត៍គ្មានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតអាជីវកម្ម ឬប្រកាសលក់មុនទទួលបានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតអាជីវកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ៥០.០០០.០០០(ហាសិបលាន)រៀល។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះ ត្រូវគុណទ្វេដង រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់ការបន្ត។

**ប្រការ៤៥.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលប្រើប្រាស់អាជ្ញាបណ្ណឬលិខិតអនុញ្ញាតអាជីវកម្មហួសសុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ១.០០០.០០០(មួយលាន)រៀល ក្នុង០១(មួយ)ថ្ងៃ សម្រាប់រយៈពេល ៣០(សាមសិប)ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះត្រូវគុណទ្វេដងក្នុង ០១(មួយ)ថ្ងៃ។

**ប្រការ៤៦.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើឱ្យបាត់បង់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មច្បាប់ដើម មុនពេលគម្រោងសាងសង់ចប់ជាស្ថាពរ ឬក្លែងបន្លំអាជ្ញាបណ្ណឬលិខិតអនុញ្ញាតអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរ ចំនួន ៤០.០០០.០០០(សែសិបលាន)រៀល និងត្រូវផ្អាកអាជីវកម្មជាបណ្ដោះអាសន្នរហូតមានការអនុញ្ញាតពីក្រសួង ទើបអាចដំណើរការអាជីវកម្មជាថ្មីឡើងវិញបាន។

**ប្រការ៤៧.**

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ ដែលបើកនិងដំណើរការគណនីផ្សេង ដើម្បីទទួលប្រាក់របស់អ្នកទិញ ក្រៅពីគណនីអភិវឌ្ឍអចលនវត្ថុ ត្រូវទទួលពិន័យអន្តរ-ការណ៍ពីក្រសួងឬមន្ទីរ ចំនួន ១០.០០០.០០០(ដប់លាន)រៀល។

**ប្រការ៤៨.**

អំពើលក់ ឬផ្សាយពាណិជ្ជកម្មលក់អចលនវត្ថុ ដោយមិនអនុលោមតាមប្រការ១៨ ប្រការ១៩ ប្រការ២០ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរ ចំនួន ១.០០០.០០០(មួយលាន)រៀល ក្នុង០១(មួយ)ថ្ងៃ សម្រាប់រយៈពេល ៣០(សាមសិប)ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះត្រូវគុណទ្វេដងក្នុង ០១(មួយ)ថ្ងៃ។

**ប្រការ៤៩.**

អ្នកអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ ដែលដកប្រាក់ពីក្នុងគណនីអភិវឌ្ឍអចលនវត្ថុ ផ្ទុយនឹងប្រការ៣២ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ១០.០០០.០០០(ដប់លាន)រៀល ក្នុង ០១(មួយ)ករណី។

**ប្រការ៥០.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលខកខានពុំផ្ដល់របាយការណ៍តាមការកំណត់ដូចមានចែងក្នុងប្រកាសនេះ ឬផ្ដល់

ព័ត៌មានមិនពិតនៅក្នុងរបាយការណ៍ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ៥០០.០០០(ប្រាំរយពាន់)រៀល ក្នុង ០១(មួយ)ថ្ងៃ សម្រាប់រយៈពេល ៣០(សាមសិប)ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះ ត្រូវគុណទ្វេដងក្នុង ០១(មួយ)ថ្ងៃ។

**ប្រការ៥១.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលមិនបន្តសុពលភាពបណ្ណធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន តាមកាលបរិច្ឆេទកំណត់ ឬមានការយឺតយ៉ាវ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ៥០០.០០០(ប្រាំរយពាន់)រៀល ក្នុង០១(មួយ)ថ្ងៃ សម្រាប់រយៈពេល ៣០(សាមសិប)ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះត្រូវគុណទ្វេដងក្នុង ០១(មួយ)ថ្ងៃ។

**ប្រការ៥២.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលមិនបន្តសុពលភាពលិខិតដាក់ប្រាក់តម្កល់ធានាអាជីវកម្មតាមកាលបរិច្ឆេទកំណត់ ឬមានការយឺតយ៉ាវ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ៥០០.០០០(ប្រាំរយពាន់)រៀល ក្នុង ០១(មួយ)ថ្ងៃ សម្រាប់រយៈពេល ៣០(សាមសិប)ថ្ងៃដំបូង ។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះ ត្រូវគុណទ្វេដងក្នុង ០១(មួយ)ថ្ងៃ។

**ប្រការ៥៣.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលដកប្រាក់តម្កល់ធានាអាជីវកម្មដោយគ្មានការអនុញ្ញាតពីក្រសួង ឬមន្ទីរ ត្រូវទទួលពិន័យអន្តរការណ៍ចំនួនទ្វេដង នៃប្រាក់តម្កល់។ ក្នុងករណីមិនព្រមបង់ប្រាក់ផាកពិន័យនេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ ឬប្ដឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមនីតិវិធីបន្ត។

**ប្រការ៥៤.**

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលសាងសង់លំនៅឋាន ឬអគារសហកម្មសិទ្ធិលើសចំនួនដែលបានស្នើសុំនៅក្នុងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ២.០០០.០០០(ពីរលាន)រៀល ក្នុង ០១(មួយ)ឯកតា។ ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ផាកពិន័យនេះ ត្រូវគុណទ្វេដងក្នុង ០១(មួយ)ឯកតា។

**ប្រការ៥៥.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលអនុវត្តគម្រោងអភិវឌ្ឍដីឡូត៍ខុសគោលការណ៍កំណត់របស់ក្រសួង ស្ថាប័ននិងអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ៣០.០០០.០០០(សាមសិបលាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៥៦.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលអនុវត្តខុសកិច្ចសន្យាលក់-ទិញ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ១០.០០០.០០០(ដប់លាន)រៀល ក្នុង ០១(មួយ)ករណី។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៥៧.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលមិនអនុវត្តតាមសៀវភៅបន្ទុក ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរ

ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៥៨.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ១០.០០០.០០០(ដប់លាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៥៩.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិប្រភេទ១ ប្រកាសលក់អចលនវត្ថុមុនគម្រោងសាងសង់ចប់ជាស្ថាពរ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៦០.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលខកខានមិនបានកាន់កាប់បញ្ជីគណនេយ្យត្រឹមត្រូវ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ២.០០០.០០០(ពីរលាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៦១.**

លទ្ធផលនៃការធ្វើសវនកម្មបង្ហាញថា មានភាពខុសគ្នាពាក់ព័ន្ធរបាយការណ៍ប្រចាំខែ និងរបាយការណ៍ប្រចាំត្រីមាស ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ២.០០០.០០០(ពីរលាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៦២.**

អ្នកអភិវឌ្ឍអចលនវត្ថុដែលមិនអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួង ឬមន្ទីរចំនួន ៤.០០០.០០០(បួនលាន)រៀល។ ក្នុងករណីមិនរាងចាល ពិន័យអន្តរការណ៍ នឹងត្រូវគុណទ្វេដង។

**ប្រការ៦៣.**

ប្រាក់ជាកពិន័យដែលមានចែងក្នុងប្រការ៤៤ ដល់ប្រការ៦២ ត្រូវបង់ចូលគណនីចរន្តសម្រាប់ប្រតិបត្តិការចំណូលរបស់រតនាគារជាតិ ឬរតនាគាររាជធានី-ខេត្ត នៅធនាគារពាណិជ្ជដៃគូ តាមដីការអមរបស់នាយកដ្ឋាន ឬមន្ទីរ។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**ប្រការ៦៤.**

អាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន ដែលក្រសួងផ្តល់ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន មុនពេលដាក់ឱ្យអនុវត្តប្រកាសនេះ នៅបន្តមានសុពលភាពអនុវត្តរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

គ្រប់គម្រោងអភិវឌ្ឍដីឡូត៍ ដែលកំពុងដំណើរការលក់ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍដីឡូត៍ នៅពេលដែលប្រកាសនេះចូលជាធរមាន។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**ប្រការ៦៥.**

ប្រកាសលេខ ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦៦.**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១ រោច ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី ខេត្ត
- ដូចប្រការ៦៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ